## Excusing oneself



១ ធារី៖ អាឡូ វឌ្ឍនៈ ខ្ញុំធារីអ៊ា។ ម៉េចហើយ? ជិតមកដល់នៅ?
វឌ្ឍនៈ៖ ធារីអ៊ំ? ចុម! ង៉ៃហ្នឹងង៉ៃអីគេ?
ធារី៖ ង៉ៃសៅរ៍។ ក្រែងណាត់គ្នាម៉ោង ៥ អ៊េ?
វឌ្ឍនៈ៖ អូ ធារី ខ្ញុំច្រឡំ ស្មានតែង៉ៃហ្នឹងង៉ៃសុក្រ។ ខ្ញុំទៅអត់ទាន់អ៊េ ធារី ណាត់ង៉ៃផ្សេងបានអ៊េ? សុំទោសណា។
ធារី៖ ដឹងអីចឹង តេសួរវឌ្ឍនៈឯងមុន កុំឲ្យមកខក។ អត់អីទេអីចឹង ចាំង៉ៃក្រោយក៏បាន។

២ កន្និកា៖ ធារី ចេញពីធ្វើការ ទៅញ៉ាំអីជុំគ្នាអី? វឌ្ឍនៈទៅដែរតាស។
ធារី៖ ញ៉ាំអីជុំគ្នាអ៊ំ? អឹម ... ល្ងាចហ្នឹង ខ្ញុំរៀងរវល់នៅផ្ទះតិច។ ចាំង៉ៃក្រោយទៅណា។
កន្និកា៖ ធារី បបួលម្ដងណាក៏រវល់ដែរ។
ធារី៖ បើឆ្លៀតបាន ខ្ញុំចង់ទៅដែរហ្នឹង។
កន្និកា៖ មានអី ថាលេងតាស។

| | |
|---|---|
| ធារី / កន្និកា / វឌ្ឍនៈ | female / female / male Cambodian names |
| អ៊ា | spoken form of ណា = particle used to soften a statement or request |
| អ៊ំ | spoken form of ឬ = particle used to form a yes/no question |
| ចុម | exclamation expressing (mostly negative) surprise |
| ង៉ៃ | spoken form of ថ្ងៃ = day |
| ក្រែង ... អ៊េ | = ក្រែង ... ត្រូវទេ? = Isn’t it ...?, Aren’t we ...? etc. |
| អ៊េ | spoken form of the question or negation particle ទេ |
| ដឹងអីចឹង ... | Had I known [that] ... |
| តេ | to call someone (by phone) |
| មកខក | to waste time to come, to come in vain/for nothing |
| តាស | particle in final position used to affirm the preceding |
| រៀង ... តិច | to be a bit ... (+ adjective) |
| បបួលម្ដងណាក៏រវល់ដែរ | whenever I invite you, you’re busy |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| ឆ្លៀត | to find time |
| មានអី | no problem |
| ថាលេងតាស | I'm just joking |

## Cultural notes

នៅប្រទេសជប៉ុន ប្រសិនបើអ្នកនិយាយថាជាប់រវល់ ទោះវាជាលេសក៏ដោយ គេក៏នឹងមិនសួរដេញដោលអ្នកទៀតដែរ ព្រោះគេគិតថាជារឿងផ្ទាល់ខ្លួន។ ប៉ុន្តែនៅខ្មែរ នៅពេលអ្នកយកលេសថារវល់ ភាគច្រើនអ្នកអាចនឹងត្រូវបានគេសួរបន្តទៀតថារវល់នឹងអ្វីឲ្យច្បាស់លាស់។

| | |
|---|---|
| ជប៉ុន | Japan |
| ជាប់រវល់ | to be busy |
| លេស | excuse, pretext |
| ដេញដោល | to interrogate, to keep asking |
| យកលេស | to make an excuse |
| ច្បាស់លាស់ | surely |

## Additional dialogue

ប្រធាន៖ កន្និកា ម៉េហ្នឹងដូចរៀងយឺតអ៉េ?
កន្និកា៖ ចាសបង អាឡៃងតាស្ទះចរាចរណ៍។
ប្រធាន៖ ចុះធ្វើឯកសារឲ្យបងហើយនៅ?
កន្និកា៖ អត់ទាន់ហើយផងបង។ ម្សិលមិញ ខ្ញុំអត់សូវស្រួលខ្លួន។
ប្រធាន៖ ធ្វើម៉េហ្នឹងឲ្យហើយមកអីចឹង។

| | |
|---|---|
| ប្រធាន | boss, line manager |
| អាឡៃងតា ... | spoken form of រវល់តែ ... = I was caught up in ... |
| ស្ទះចរាចរណ៍ | traffic jam |
| អត់សូវស្រួលខ្លួន | to be not so well |
| ធ្វើឲ្យហើយ | to finish |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.